**ជំពូកទី ១១**

# ការជំរុញដំបូង និងសកម្មភាពវិវត្តន៍
## (Early Stmulation and Development Activities)

នៅក្នុងទំព័របន្ទាប់គឺជាសកម្មភាពសំរាប់ជួយដល់ការវិវត្តន៍របស់កុមារក្មេងៗ។ សកម្មភាពទាំងនោះមានតំលៃជាពិសេសចំពោះកុមារដែលយឺតខាងប្រាជ្ញា និងខាងរាងកាយ។ វាក៏មានប្រយោជន៍ចំពោះកុមារដែលមានប្រាជ្ញាធម្មតាដែរ ប៉ុន្តែសំរាប់កុមារពិការរាងកាយដែលមានភាពយឺត និងពិបាកបង្កើតឱ្យមានការវិវត្តន៍ទាំងកាយ និងប្រាជ្ញា។

នៅក្នុងជំពូកនេះ យើងពិពណ៌នាពីសកម្មភាពទាំងឡាយសំរាប់ជំនាញដំបូងតាមលំដាប់ដែលពួកគេវិវត្តតាមធម្មតា។ ដូចនេះយើងចាប់ផ្តើមពីការគ្រប់គ្រងក្បាល បន្ទាប់មកឈានទៅកំរិតនៃការរីកចំរើនច្រើនឯទៀតដូចជា: ការឈោង ការចាប់ ការអង្គុយលំនឹង ការអង្គិលឬវារ ការឈរ ការដើរ និងភាសា។ (សកម្មភាពថែរក្សាដោយខ្លួនឯងរួមមាន ការញ៉ាំ ស្លៀកពាក់ និងការបណ្តុះបណ្តាលការប្រើបង្គន់ត្រូវបានលើកយកមកពិភាក្សានៅក្នុងជំពូកបន្ទាប់)។



នៅក្នុងចំនុចខ្លះនៃការវិវត្តន៍ដូចជា ការគ្រប់គ្រងក្បាល ឬការប្រើដៃ កុមារក៏លូតលាស់តាមដំណាក់កាលនៃសមត្ថភាពផ្សេងគ្នាដែរ។ ឧទាហរណ៍ ក្នុងការវិវត្តន៍នៃការក្តាប់ដៃ ដំបូងកុមារគ្រាន់តែអាចចាប់ដោយប្រើដៃទាំងអស់ បន្ទាប់មកចាប់ដោយប្រើតែមេដៃ និងម្រាមដៃ។

ដើម្បីសំរេចថាសកម្មភាពណាគួរចាប់ផ្តើម ចូរផ្តើមដោយប្រើតារាងដើម្បី**កំណត់កំរិតការវិវត្តន៍**របស់កុមារ។ បន្ទាប់មក ចូរមើលទំព័រ ១២០ រហូតដល់ទំព័រ ១៣៤ **និងធ្វើការជ្រើសសកម្មភាពទាំងនេះ ដែលនៅបន្ទាប់ក្នុងជួរសំរាប់កុមារ**។ ក្រោយពីកុមាររៀនសកម្មភាពទាំងនេះរួច ចូរបន្តទៅចំនុចបន្ទាប់។

**កុមារលូតលាស់តាមចំនុចជាច្រើននៃការវិវត្តន៍ភ្លាមៗ**។ ចូរព្យាយាមជួយកុមារជាច្រើនចំនុចនៅពេលដូចគ្នា។ **ក្នុងចំនុចនិមួយៗ ចូររើសសកម្មភាពទាំងឡាយណា ដែលជួយឱ្យគេធ្វើបានប្រសើរជាងអ្វីដែលគេបានធ្វើ រួចឈានទៅជំហ៊ានបន្ទាប់**។



ជារឿយៗសកម្មភាពដែលជួយឱ្យកុមារវិវត្តនៅក្នុងចំនុចមួយ ក៏ជួយនៅក្នុងចំនុចផ្សេងដែរ។

ឧទាហរណ៍ យើងដាក់សកម្មភាពនេះដោយមានរូបភាពពីក្រោម "**ការគ្រប់គ្រងក្បាល**"។ ប៉ុន្តែសកម្មភាពនេះក៏ជួយឱ្យវិវត្តន៍ការប្រើ**វិញ្ញាណ**ដែរ (ដូចជា ភ្នែក ការប៉ះ សំលេង) **ការគ្រប់គ្រងដៃ ការសហការដៃ-ភ្នែក លំនឹងពេលអង្គុយ** និង**ភាពបត់បែនរបស់សពាង្គកាយ** (ងាកទៅផ្នែកម្ខាង)។ ប្រសិនបើត្រូវបានធ្វើរួចដោយវិធីជិតស្និទ្ធ ដោយការសរសើរ វាអាចបង្កើតអោយមាន**ភាពជឿជាក់** និង**សមត្ថភាពទំនាក់ទំនង**ទៅកាន់អ្នកដទៃ។ ហើយប្រសិនបើឪពុកនិយាយទៅកាន់កូន នៅពេលពួកគេលេងដោយប្រាប់ឈ្មោះវត្ថុ និងសកម្មភាពនិមួយៗ វាក៏រៀបចំឱ្យកុមាររៀនភាសាផងដែរ។

នៅពេលជួយកូនរបស់អ្នកដោយប្រើសកម្មភាពសិក្សាទាំងនេះ ចូរចងចាំថាត្រូវតែណែនាំ**ជំនាញថ្មី នៅក្នុងជំហ៊ានតូចៗ** ដែលកុមារអាចរៀនតាមដោយងាយ។ ចូរសរសើរគេ ជារៀងរាល់ពេលដែលគេទទួលបានជ័យជំនះ ឬពេលដែលគេខិតខំព្យាយាម។ ចូរធ្វើតាមការស្នើសុំនៅទំព័រទី ១១៧ ដើម្បីជួយកុមារឱ្យវិវត្តជំនាញថ្មីៗទាំងនេះ។

> ***ប្រយ័ត្ន:*** សកម្មភាពមួយចំនួននៅក្នុងជំពូកនេះ មានសារៈសំខាន់សំរាប់កុមារដែលមានជំងឺខូចខួរក្បាល ឬកុមារពិការរាងកាយ។ ប៉ុន្តែសកម្មភាពមួយចំនួនត្រូវតែធ្វើការផ្លាស់ប្តូរ ឬទទួលតាម។ ចូរអានជំពូកដែលអនុវត្តចំពោះកុមារពិការ។ ***ជាពិសេស:*** ចូរប្រើការគិតរបស់អ្នក។ ចូរសង្កេតវិធីដែលកូនរបស់អ្នកធ្វើ។ ចូរចំណាំពីសកម្មភាពជួយ ឬរាំងការវិវត្តន៍ទាំងស្រុងរបស់កុមារ។ **មិនគ្រាន់តែធ្វើតាមការបង្ហាត់បង្ហាញនេះទេ ចូរទទួលតាម ឬផ្លាស់សកម្មភាពដែលឆ្លើយតបនិងតំរូវការរបស់កុមារ។**

## ១. សកម្មភាពជួយកុមារឱ្យចេះលើក និងគ្រប់គ្រងក្បាលរបស់ខ្លួន(និងការប្រើភ្នែក និងត្រចៀករបស់កុមារ)

ជំនាញមួយក្នុងជំនាញទាំងអស់ដំបូងដែលកុមារធម្មតាវិវត្តគឺសមត្ថភាពលើកក្បាល និងគ្រប់គ្រងចលនារបស់វា។ ការគ្រប់គ្រងក្បាលត្រូវការមុនពេលកុមារអាចរៀនក្រឡាប់ អង្គុយ ឬវារ។ តាមធម្មតាកុមារទើបតែកើតមកអាចលើកក្បាល ឬទប់ក្បាលរបស់គេឡើងបានមួយរយៈ រួចកុមារវិវត្តការគ្រប់គ្រងក្បាលបានល្អមធ្យមនៅក្នុងខែដំបូងនៃជីវិត។ **កុមារដែលមានការវិវត្តន៍យឺតតែងតែវិវត្តការគ្រប់គ្រងក្បាលយឺត។ យើងត្រូវការជួយពួកគេដើម្បីឱ្យវិវត្តការគ្រប់គ្រងក្បាលសមស្រប មុនពេលព្យាយាមជួយគេឱ្យក្រឡាប់ អង្គុយ វារ ឬដើរ។**

លើកទឹកចិត្តកុមារឱ្យងើបក្បាល នៅពេលមុខគេអោនចុះ ចូរទាញការយកចិត្តទុកដាក់របស់កុមារ ដោយប្រើវត្ថុដែលមានពណ៌ភ្លឺ ដែលធ្វើអោយចំឡែក ឬមានសំលេងពិរោះ។



ប្រសិនបើកុមារមិនងើបក្បាលឡើង ជួយដាក់គេដូចនេះ។ សង្កត់ខ្លាំងបន្តិចលើសាច់ដុំផ្នែកនីមួយៗនៃឆ្អឹងខ្នង រួចរុញដៃរបស់អ្នកយឺតៗពីក មកចង្កេះ។



ប្រសិនបើកុមារមានបញ្ហាក្នុងការងើបក្បាល ដោយសារតែខ្នង ឬស្មាខ្សោយ ចូរព្យាយាមដាក់ភួយពីក្រោមទ្រូង និងស្មារបស់គេ។ ចុះក្រោមនៅពីមុខកុមារ រួចនិយាយទៅកាន់គេ ឬដាក់គ្រឿងលេងក្នុងរង្វង់ដែលឈោងដល់ ដើម្បីជំរុញការចាប់អារម្មណ៍ និងចលនា។



កុមារខ្លះអាចធ្វើបានច្រើន ប្រសិនបើពួកគេដេកនៅលើ "ជ្រុង"

ប្រសិនបើកុមារមានបញ្ហាក្នុងការងើបក្បាល នៅពេលមុខគេអោនចុះ ចូរដាក់គេទល់នឹងខ្លួនរបស់អ្នក ដូចនេះកុមារស្ទើរតែបញ្ឈរត្រង់។ វិធីនេះកុមារត្រូវការកំលាំងតិចដើម្បីងើបក្បាលរបស់គេ។




ជួយកុមារឱ្យវិវត្តការគ្រប់គ្រងក្បាល នៅពេលដេកផ្ងារ ចូរកាន់កំភួនដៃ រួចទាញគេឡើងតិចៗរហូតដល់ក្បាលរបស់គេធ្លាក់ចុះបន្តិច បន្ទាប់មកដាក់គេឱ្យដេកវិញ។



***ប្រយ័ត្ន:* ចូរកុំទាញកុមារឡើងដូចនេះ ប្រសិនបើក្បាលរបស់គេធ្លាក់ចុះ។**
នៅពេលដែលអ្នកចាប់ផ្តើបលើកគេ ចូរមើលក្រែងសាច់ដុំករបស់គេតឹង។ ប្រសិនបើមិនតឹងទេ ចូរកុំទាញគេឡើង។ ចូរកុំទាញកុមារឡើងដូចនេះផងដែរ ក្រែងវាបណ្តាលឱ្យជើងរបស់គេលាតត្រង់រឹង(មើល "ជំងឺខូចខួរក្បាលទំព័រ ៣៤)



ប្រសិនបើកុមារមានជំងឺខូចខួរក្បាលឡើងរឹង នៅពេលដែលអ្នកទាញដៃរបស់គេចូរព្យាយាមទាញស្លាបប្រជៀវស្មាទៅមុខ នៅពេលអ្នកលើកគេឡើង។



ប្រសិនបើកុមារមិនអាចលើកក្បាលបាននៅពេលទាញគេឡើង ចូរកុំទាញគេអី ។ ជាជំនួសចូរដាក់គេឱ្យអង្គុយឡើង ដាក់ឱ្យផ្អៀងក្រោយថ្នមៗ ដោយលើកទឹកចិត្តកុមារឱ្យទប់ក្បាលរបស់គេឡើង ។ ចូរធ្វើច្រំដែលឱ្យបានញឹកញាប់ ហើយនៅពេលដែលគេមានកំលាំង និងមានការគ្រប់គ្រង ចូរផ្អៀងគេទៅក្រោយបន្តិចម្តងៗ ប៉ុន្តែមិនត្រូវឱ្យក្បាលរបស់កុមារធ្លាក់ចុះក្រោមទេ ។



ប្រសិនបើទារកស្ទើរតែគ្មានលទ្ធភាពលើក ឬទប់ក្បាលរបស់ខ្លួននៅពេលដែលអ្នកបំបៅគេ ជាជំនួសពីការដាក់ក្បាលសុដន់ ឬអាហារទៅក្នុងមាត់របស់គេដោយគ្រាន់តែធ្វើឱ្យក្បាលសុដន់ ឬអាហារប៉ះមាត់របស់កុមាររួចធ្វើឱ្យគេមករកក្បាលសុដន់ឬអាហារនោះដោយខ្លួនឯងវិញ ។



## ទីតាំងបីដែលល្អ

បីកុមារយ៉ាងដូចនេះដើម្បីជួយវិវត្តការគ្រប់គ្រងក្បាលបានល្អនៅពេលដែលកុមារអោនមុខចុះ



ទីតាំងដែលដាក់ត្រគាក និងជង្គង់ឱ្យបត់ ហើយជង្គង់ញែកចេញពីគ្នាជួយឱ្យមានការសំរាក និងគ្រប់គ្រងប្រសើរឡើង ចំពោះកុមារដែលមានជំងឺខូចខួរក្បាល  សពាង្គកាយលាតត្រង់ រឹង និងជង្គង់អោបចូលគ្នា



បីកុមារដូចនេះធ្វើឱ្យក្បាលនិងដៃរបស់គេធ្វើចលនានិងត្រឡេកមើលជុំវិញដោយសេរី



នៅពេលកូនរបស់អ្នកមានការវិវត្តន៏នៃការគ្រប់គ្រងក្បាលប្រសើរឡើង ចូរលេងជាមួយគេ ដោយទប់ទ្រកាយរបស់គេឱ្យជាប់ ប៉ុន្តែទុកក្បាល និងដៃឱ្យទំនេរ ។



## ២. សកម្មភាពលើកទឹកចិត្តការក្រឡាប់ និងការងាក

បន្ទាប់ពីទារកមានការគ្រប់គ្រងក្បាលបានល្អមធ្យម ជាធម្មតាជំហ៊ានបន្ទាប់ក្នុងការវិវត្តន៍គឺក្រឡាប់។ ការក្រឡាប់ទាក់-ទងនិងការងាកក្បាល និងខ្លួនទៅចំហៀង។ ការងាក ឬ**បង្វិលខ្លួនផ្នែកខាងលើ ពីលើចុះក្រោមត្រូវបានសិក្សាមុនពេលកុមារអាចវារៀនវារ និងក្រោយមកដើរ**។

តាមធម្មតាទារករៀនក្រឡាប់ចុះឡើងដោយខ្លួនឯង។ ប៉ុន្តែកុមារដែលវិវត្តយឺតនឹងរៀនបានលឿនជាមួយជំនួយពិសេស និងការលើកទឹកចិត្ត។ ជាដំបូង ចូរជួយកុមាររៀនលើក និងក្រឡប់ក្បាលទៅម្ខាង បន្ទាប់មកស្មា និងខ្លួន។

ទាក់ទាញការចាប់អារម្មណ៍របស់កុមារ ដោយកាន់ប្រដាប់ទារកអង្រន់លេង ឬប្រដាប់លេងពីមុខរបស់គេ

លើកទឹកចិត្តកុមារឱ្យឈោងយកប្រដាប់លេងពីចំហៀងខ្លួន



បន្ទាប់មករំកិលប្រដាប់លេងទៅម្ខាង ដូចនេះកុមារនឹងងាកក្បាល និងស្មាតាមវត្ថុនោះ

បន្ទាប់មករំកិលប្រដាប់លេងឡើងលើ ដូចនេះកុមារនឹងបង្វិលទៅចំហៀង និងបង្វិលខ្នង។

ប្រសិនបើកុមារមិនក្រឡាប់ទេ បន្ទាប់ពីមានការព្យាយាមជាច្រើនលើក ចូរជួយកុមារដោយលើកជើងរបស់គេម្ខាង។




***ចំណាំ :*** ប្រសិនបើកុមារផ្លាស់ប្តូរ អ្នកអាចត្រូវការទីតាំងជាជំនួយសំរាប់ដៃនេះ មុនពេលដែល គេក្រឡាប់។

ថែមទាំងជួយកុមារឱ្យរៀនក្រឡាប់ពីខាងខ្នងមកចំហៀង។ ឱ្យគេឈោងចាប់ប្រដាប់លេង ដែលបានកាន់នៅផ្នែកម្ខាងសារជាថ្មី។



***ចំណាំ :*** ប្រសិនបើកុមាររឹងខ្លាំងមុនពេលធ្វើលំហាត់ប្រាណ ឬសកម្មភាពផ្សេងៗ ដំបូងជួយឱ្យគេសំរាក ដោយយោងជើងរបស់គេទៅក្រោយទៅមុខៗ



ឬមូរកុមារជា "រាងបាល់" និងបង្វិលត្រគៀកនិងជើង ដោយយឺតៗពីម្ខាងទៅម្ខាង






ឬបង្វិលខ្លួនរបស់គេទៅម្ខាងរួចទៅម្ខាងទៀត។ ជួយកុមារឱ្យឈោងយកអ្វីមួយដែលគេចូលចិត្ត។ ចូរសរសើរគេនៅពេលដែលគេឈោងដៃ។

***ចំណាំ:*** ច្បាប់ដំបូងរបស់***វិធីព្យាបាលរោគ*** : ជួយឱ្យបានច្រើនពេលតាមតម្រូវការ ដោយលើកទឹកចិត្តកុមារឱ្យធ្វើលំហាត់ជាច្រើនសំរាប់ខ្លួនគេផ្ទាល់។

# ៣. សកម្មភាពជួយដល់ការវិវត្តន៍នៃការកាន់ក្ដាប់ ការឈោង និងការប្រើដៃ-ភ្នែក

កុមារភាគច្រើនកើតមកដោយមាន "រ៉េផ្លិចនៃការកាន់ក្ដាប់"។ ប្រសិនបើអ្នកដាក់ម្រាមដៃក្នុងដៃរបស់គេ ដៃនោះនឹងកាន់ក្ដាប់ម្រាមដៃយ៉ាងណែនដោយស្វ័យប្រវត្តិ ដោយអ្នកអាចលើកដៃរបស់គេឡើងលើបាន



ជាធម្មតាការរ៉េផ្លិចនេះនឹងបាត់ ហើយជាបណ្ដើរៗទារករៀនកាន់វត្ថុ និងទំលាក់ចោលនៅពេលគេជ្រើសរើស។

ទារកដែលយឺតក្នុងការវិវត្តន៍ ជួនកាលមាន ឬគ្មាន "រ៉េផ្លិចកាន់ក្ដាប់" ហើយយឺតក្នុងការរៀនកាន់វត្ថុ។ ចំពោះកុមារបែបនេះ សកម្មភាពទាំងនេះអាចជួយគេបាន។

ប្រសិនបើគេក្ដោប់ដៃ ចូរអង្អែលផ្នែកខាងក្រៅគែមដៃ ពីកូនដៃទៅកាន់កដៃ

វិធីនេះជារឿយៗធ្វើឱ្យទារកលើក និងលាដៃរបស់គេ រួចកាន់ក្ដាប់ម្រាមដៃរបស់អ្នក



***ប្រយ័ត្ន :*** ចំពោះកុមារដែលមានការលំបាក ការអង្អែលខ្នង ដៃអាចធ្វើឱ្យដៃរបស់គេក្ដាប់ ឬលាយ៉ាងរឹងដោយគ្មានការគ្រប់គ្រង។ ប្រសិនបើដូចនេះ ចូរកុំអង្អែល ប៉ុន្តែរកវិធីដែលធ្វើឱ្យគេមានការគ្រប់គ្រងបានច្រើន។



នៅពេលកុមារលាដៃរបស់គេបានល្អ ប៉ុន្តែគេមានបញ្ហាក្នុងការកាន់

ចូរដាក់វត្ថុមួយនៅក្នុងដៃរបស់គេ រួចពត់ម្រាមដៃរបស់គេជុំវិញវត្ថុនោះ។ ចូរប្រាកដថា មេដៃមានទិសផ្ទុយពីម្រាមដៃ។



ជាបណ្ដើរៗប្រលែងដៃរបស់គេ រួចទាញវត្ថុនោះឡើងទល់និងម្រាម ឬមួលពីម្ខាងទៅម្ខាងចុះឡើងៗ



ពេលអ្នកគិតថា កុមារកាន់ក្ដាប់បានណែនហើយ ចូរប្រលែងវា។




ចូរធ្វើច្រំដែលបីបួនលើកសំរាប់ដៃម្ខាងៗរបស់កុមារ។



បន្ទាប់ពីកុមារអាចកាន់វត្ថុដែលដាក់នៅក្នុងដៃរបស់គេ ចូរលើកទឹកចិត្តកុមារឱ្យឈោង និងកាន់ក្ដាប់វត្ថុដែលគ្រាន់តែប៉ះចុងម្រាមដៃរបស់គេ។ ដំបូងប៉ះផ្នែកខាងលើនៃដៃ បន្ទាប់មកដាក់វានៅខាងក្រោមចុងម្រាមដៃ។



លើកទឹកចិត្តទារកឱ្យក្ដាប់ ដោយផ្ដល់ឧបករណ៍អង្រួនលេងកន្ទឹងតុក្កតាដែលមានពណ៌ច្រើន ឬអ្វីសំរាប់ញ៉ាំដោតជាមួយឈើ

ចូរព្យួរប្រដាប់លេង កន្ទឹង ឧបករណ៍អង្រួនដែលគួរឱ្យចាប់អារម្មណ៍ នៅកន្លែងដែលកុមារអាចមើលឃើញ និងឈោងចាប់បាន។



វិធីនេះកុមាររៀនធ្វើចលនាដៃរបស់ខ្លួនទៅមុខដើម្បីចាប់ប្រដាប់លេង។

ប្រសិនបើកុមារមិនដឹងពីដៃរបស់ខ្លួន ចូរបំពាក់កន្ទឹងបន្តិចនៅលើដៃរបស់គេ។



មើលពីវិធីជួយកុមារឱ្យដឹងពីដៃរបស់ខ្លួន ដោយដាក់អាហារផ្អែម នៅលើម្រាមដៃ និងជួយកុមារឱ្យដាក់ចំណីនោះចូលទៅក្នុងមាត់របស់គេ។

ដំបូងកុមារអាចកាន់ក្ដាប់វត្ថុធំ ដោយដៃទាំងមូលរបស់ខ្លួន នៅពេលដែលកុមារធំឡើង គេនឹងអាចរើស ឬកាន់វត្ថុតូច ដោយប្រើមេដៃ និងម្រាមដៃ។ ជួយគេឱ្យប្រើម្រាមដៃ ដោយលេងជាមួយវត្ថុដែលមានទំហំខុសគ្នា។



ដើម្បីជួយអោយក្ដាប់បានណែន ចូរលេងល្បែង "ទាញព្រាត់" ជាមួយកុមារ ដោយធ្វើវាជាល្បែងកំសាន្តសប្បាយ។




នៅពេលដែលកុមារមានការគ្រប់គ្រងបានច្រើន ចូរណែនាំប្រដាប់លេង និងល្បែងដែល**ជួយវិវត្តន៍ផ្នែកនៃការប្រើដៃ-ភ្នែក**។ សំរាប់គំនិតផ្សេងៗ មើលទំព័រទី ១៣៦។



លេងល្បែងដាក់វត្ថុក្នុង និងក្រៅប្រអប់ ឬក្រឡ។

លេងជាមួយប្រដាប់លេង គ្រាប់តាមកិច្ចការ និងលេងល្បែងដទៃទៀត ជួយឱ្យកុមារទទួលបានការប្រើដៃដ៏ប្រសើរ។

## ៤. សកម្មភាពសំរាប់គ្រប់គ្រងខ្លួន លំនឹង និងការអង្គុយ

បន្ទាប់ពីកុមារទទួលបានការគ្រប់គ្រងក្បាលបានល្អ តាមធម្មតាកុមារចាប់ផ្ដើមអង្គុយតាមរយៈដំណាក់កាលទាំងនេះ:

អង្គុយនៅពេលដាក់ក្នុងទីតាំងអង្គុយ និងត្រូវកាន់ទប់



អង្គុយដោយរក្សាលំនឹងជាមួយដៃ



មានលំនឹងជាមួយខ្លួននៅពេលអង្គុយ ដៃទំនេរសំរាប់លេង



ក្រោកអង្គុយពីទីតាំងដេកដោយឯកឯង



ដើម្បីអង្គុយបានល្អ កុមារត្រូវការសមត្ថភាពដើម្បីទប់ខ្លួនឡើង ប្រើដៃចាប់ និងទ្រកាយដោយខ្លួនឯង និងទីបញ្ចប់ធ្វើឱ្យមានលំនឹងដល់ខ្លួន ដើម្បីឱ្យកុមារអាចប្រែ និងឈោងចាប់បាន។

ប្រសិនបើកុមារដួលនៅពេលអ្នកដាក់ឱ្យគេអង្គុយ ជួយកុមារបង្កើតឱ្យមានប្រតិកម្មការពារដោយប្រើដៃរបស់គេ។ ចូរដាក់គេនៅលើកំណាត់ឈើ កាន់ត្រគៀករបស់គេ រួចក្រឡាប់គេទៅចំហៀងខ្លួនយឺតៗ។ លើកទឹកចិត្តកុមារឱ្យចាប់ដោយខ្លួនឯង។




ឬធ្វើដូចគ្នាជាមួយកុមារ ដោយប្រើពោះរបស់អ្នក



បន្ទាប់ពីកុមាររៀន "ចាប់" ដោយខ្លួនឯង នៅពេលដេកដាក់ឱ្យគេអង្គុយ កាន់ទប់ផ្នែកខាងលើត្រគៀក និងរុញស្រាលៗពីម្ខាងទៅម្ខាង




និងទៅមុខទៅក្រោយ ដូចនេះគេអាចរៀនចាប់ និងទ្រខ្លួនដោយដៃរបស់គេ។




***ប្រយ័ត្ន*:** កុមារអាចលើក និងងាកក្បាល មុនពេលដែលគេអាចលើកកាយបាន។

ដើម្បីជួយកូនរបស់អ្នកឱ្យមានលំនឹងក្នុងការអង្គុយ មុនដំបូង ដាក់គេឱ្យអង្គុយលើជង្គង់បែរមុខមករកអ្នក។

ក្រោយមកអ្នកអាចដាក់គេឱ្យអង្គុយបែរមុខមកក្រៅ ដែលគេអាចមើលឃើញអ្វីៗដែលកំពុងប្រព្រឹត្តទៅជុំវិញខ្លួនរបស់គេ។

កាន់គេដោយបន្ធូរៗដូចនេះ ខ្លួនរបស់គេអាចប្រែប្រួលតាមការផ្អែក។



លើកជង្គង់ម្ខាងយឺតៗផ្អែកថ្នមៗលើម្ខាងទៀត។ បន្ទាប់មកម្ខាងទៀត ធ្វើដូចនេះគេរៀនបត់ខ្លួនអោយនៅតែអង្គុយ



អ្នកអាចធ្វើដូចគ្នានេះជាមួយកុមារអង្គុយលើកំណាត់ឈើ។

នៅពេលដែលគេមានលំនឹងប្រសើរហើយ រំកិលដៃរបស់អ្នកចុះក្រោមផ្អែកត្រគៀក និងបន្ទាប់មកភ្លៅ ធ្វើដូចនេះគេពឹងការទ្រទ្ររបស់អ្នកតិចជាង។



ឱ្យអ្វីមួយទៅគេកាន់ធ្វើដូចនេះ គេរៀនប្រើកាយរបស់ខ្លួន និងមិនប្រើដៃដើម្បីរក្សាលំនឹងឡើយ។

ជាមួយកុមារមានវ័យច្រើនដែលពិបាកក្នុងការប្រើលំនឹង អ្នកអាចធ្វើដូចគ្នានៅលើ "ក្តារផ្ទៀង"។

ឬអ្នកអាចធ្វើដូចគ្នានៅលើបាល់ធំមួយ



ដំបូងចូរឱ្យកុមារកាន់ដោយខ្លួនឯង ដោយប្រើដៃរបស់គេ



ក្រោយមកមើលថា តើនាងអាចធ្វើវាដោយឱ្យកាន់ដៃនាងទាំងពីរជាមួយគ្នា។ បង្កើតវាជាល្បែង។



ផ្ទៀងវា**ទៅម្ខាង និងម្ខាងទៀត** និង**ទៅមុខទៅក្រោយ** ផងដែរ។

***សំគាល់:*** អ្នកអាចធ្វើលំហាត់បែបនេះដោយដាក់កុមារឱ្យអង្គុយលើតុ រួចរុញគេទៅក្រោយ ទៅចំហៀង និងទៅមុខតិចៗ។ ប៉ុន្តែ **ជាការប្រសើរដើម្បីផ្ទៀងអ្វីដែលគេអង្គុយលើ។**



**រុញ**គេបណ្តាលឱ្យគេ "ចាប់ដោយខ្លួនឯង" កុំឱ្យធ្លាក់ ដោយប្រើដៃរបស់ខ្លួន។

**ផ្ទៀងវា** ឱ្យវាប្រើខ្លួនរបស់វាដើម្បីរក្សាលំនឹងខ្លួន ដែលជាជំនាញដំបូងបំផុត។

ជួយកុមារអោយរៀនរក្សាលំនឹងនៅពេលដែលប្រើដៃ និងបង្វិលខ្លួន ។

អង្គុយនៅលើដី






និងអង្គុយនៅលើកំណាត់ឈើ ឬកៅអី

នៅពេលដែលកុមារចេះអង្គុយដោយខ្លួនឯង ជួយគេឱ្យរៀនក្រោកអង្គុយ

ពីដេកផ្ងារ




នៅពេលដែលកុមារចាប់ផ្ដើមងើប រុញត្រគាកខាងលើបន្តិច

និងពីដេកផ្កាប់



ដំបូងជួយនាងឱ្យលើកស្មារបស់ខ្លួន

សង្កត់ចុះ និងទ្រត្រគាក



ជួយឱ្យគេក្រឡាប់ទៅម្ខាង សង្កត់កែងដៃម្ខាង និងអង្គុយ

ជួយឱ្យកុមារក្រោកអង្គុយដោយខ្លួនឯង ។ **កុំទាញគេឡើង** ។ **សរសើរគេរាល់ពេលដែលគេធ្វើបានល្អ ឬពេលគេខំព្យាយាម** ។ ជួយគេតិចទៅៗរហូតដល់គេអាចក្រោកអង្គុយដោយឯកឯង ។

កុមារមួយចំនួននឹងត្រូវការវត្ថុជំនួយសំរាប់អង្គុយឱ្យបានល្អ ។ ដើម្បីកែលំអលំនឹង វត្ថុជំនួយគួរតែ**ទាបតាមដែលអាចធ្វើទៅបាន** និងនៅតែឱ្យកុមារអង្គុយត្រង់ ។ ជារឿយៗក្រុមគ្រួសារទប់ទ្រត្រគាកជាការគ្រប់គ្រាន់ ។ នេះជាឧទាហរណ៍ពីរ:

ចំពោះកុមារដែលត្រូវការឧបករណ៍ទប់ចង្កេះខ្ពស់ជាង កន្លែងអង្គុយកាច់ជ្រុងចម្មតា អាចធ្វើឡើងពីក្ដារខៀនឈើ ឬបង្គោលនៅលើដី ។





សំរាប់គំនិតជាច្រើនទៀត ស្ដីពីការអង្គុយ ការដាក់ទីតាំងជាពិសេស និងចំពោះឧបករណ៍ជំនួយការអង្គុយ ។

## ៥. សកម្មភាពសំរាប់លូន និងវារ

ដើម្បីរំកិលចុះឡើង ទារកមួយចំនួន ជាដំបូងចាប់ផ្តើម**លូន***



ក្រោមមក**វារ**



ឬ**អង្អិល**គូទរបស់ខ្លួន



| |
|---|
| ***ចំណាំ :*** **ទារកខ្លះមិនដែលវារទេ** ប៉ុន្តែវិវត្តដោយផ្ទាល់ពីអង្គុយ ទៅឈរ និងដើរ ។ ថាតើពួកគេវារ ឬមិនវារ ជារឿយៗអាស្រ័យទៅតាមគំរូវប្បធម៌ និងថាតើគ្រួសារលើទឹកចិត្តគេយ៉ាងណា ។ |

ប្រសិនបើកុមារអាចងើបក្បាលបានល្អ នៅពេលដែលដេកផ្កាប់ លើកទឹកចិត្តឱ្យគេផ្តើមលូនតាមវិធីទាំងនេះ:

ដាក់ប្រដាប់លេង ឬអាហារដែលកុមារចូលចិត្តឱ្យផុតពីដៃ ។

ដំបូងប្រហែលជាអាចជួយទ្រជើងរបស់គេ ។




| |
|---|
| ***ប្រយ័ត្ន :*** ប្រសិនបើកុមារមានជំងឺខូចខួរក្បាល ការទ្រជើងកុមារអាចនឹងធ្វើអោយជើងលាសណ្តូករឹង ។ ប្រសិនបើករណីនេះកើតឡើង កុំទ្រជើងរបស់គេ ។ |

ប្រសិនបើកុមារមិនអាចអង្កុញជើងលូនទៅមុខ ជួយគេដោយលើកត្រគៀក ។



ប្រសិនបើកុមារពិបាកក្នុងការលូន ឬវារ:

ដាក់ឱ្យកុមារ " ជិះ " ជង្គង់របស់អ្នក ។ លេង " ល្បែងជិះសេះ " ធ្វើចលនាជើងរបស់អ្នកឡើងចុះដោយយឺតៗ ធ្វើដូចនេះ កុមារ អាចផ្លាស់ប្តូរទំងន់ពីម្ខាងទៅម្ខាង ។

ឬដាក់កុមារពីលើធុង ឬកំណាត់ឧស ។ ដើម្បីជួយគេឱ្យទប់ទំងន់ ដោយប្រើកែងដៃត្រង់ រុញស្មាចុះឱ្យខ្លាំងរួចព្រលែង ។ ធ្វើសាចុះឡើង២បី ឬបួនលើក ។




ចូរលើកទឹកចិត្តកុមារឱ្យលើកដៃចេញពីផ្ទៃដី និងប្តូរទំងន់ទៅផ្នែកម្ខាងទៀត ។ បន្ទាប់មកជួយគេឱ្យធ្វើចលនាទៅមុខ ។



ប្រសិនបើកុមារមានបញ្ហាក្នុងការចាប់ផ្តើមវារ កាន់គេឡើង ដោយប្រើកន្សែងដូចនេះ ។ នៅពេលដែលគេមានកំលាំង បន្ធូរការទ្របន្តិចម្តងៗ ។



**ធ្វើចលនាកុមារពីម្ខាងទៅម្ខាង** ដូចនេះ គេធ្វើការផ្លាស់ប្តូរទំងន់ពីដៃម្ខាង ទៅជើងម្ខាង និងទៅម្ខាងទៀត ។



បងប្រុស និងបងស្រីអាចជួយបាន

លើកទឹកចិត្តកុមារទៅកន្លែងឈោងទី១ រកអ្វីដែលគេចង់បាន និងបន្ទាប់មកវារ

---

* អ្នកព្យាបាលរោគរបស់អាមេរិកខាងជើងប្រើពាក្យនេះនៅក្នុងវិធីផ្ទុយ ( លូន creep សំរាប់ វារ crawl និងវារ crawl សំរាប់លូន creep ) ។



អ្នកអាចព្យួរកុមារពីធ្នឹមឬមេដំបូល ឬមាត់ទ្វារដោយធ្វើដូចនេះ



កុមារដែលពិបាកដើរ អាចព្យួរជើងរបស់គេដោយទ្រដើម្បីឱ្យគេធ្វើចលនាដោយដៃរបស់គេ។

ឬធ្វើ "ប្រដាប់លូន" សាមញ្ញមួយ។



នៅពេលដែលកុមាររៀនវារបានល្អមធ្យមហើយ ឱ្យគេលេងល្បែងវារផ្សេងៗ។

គេអាចវារឡើង ឬចុះទីទួល ឬពំនូកចំប៉ើងទាបៗ។ វិធីនេះអាចជួយកែលំអរកំលាំងនិងតុល្យភាពរបស់កុមារ





ដើម្បីជួយកុមារវ័យច្រើន ដែលមានបញ្ហាលំនឹងប្រុងប្រៀបសំរាប់ដើរ លើកទឹកចិត្តកុមារឱ្យ**វារចំហៀងខ្លួន និងត្រឡប់ក្រោយ**



ឱ្យកុមារលើកជើង ឬដៃម្ខាងផុតពីផ្ទៃដី រួចផ្លាស់ប្តូរទំងន់ថយក្រោយ និងទៅមុខ



ដំបូងអ្នកអាចត្រូវការកាន់អវយវៈ លើក នៅពេលដែល អ្នកយោគគេទៅមកដោយយឺតៗពីម្ខាងទៅម្ខាង។

ក្រោយមកឱ្យគេអនុវត្តដោយលើកដៃម្ខាង និងជើងខាងផ្ទុយគ្នា ឱ្យផុតពីផ្ទៃដីក្នុងពេលតែមួយ






"ក្តារយោល" ជាល្បែងសប្បាយ និងជួយឱ្យមានលំនឹង



បន្ទាប់ពីកុមារមានលំនឹងនៅលើដៃ និងជង្គង់ អ្នកអាចជួយគេឱ្យចាប់ផ្តើមអង្គុយ និងដើរដោយប្រើជង្គង់។ កុមារអាចដើរចំហៀងខ្លួនតាមបណ្តោយខ្សែ។



***ប្រយ័ត្ន:*** កុំធ្វើដូចនេះ ជាមួយកុមារដែលពិបាក ជង្គង់របស់គេបត់ជាខ្លាំងនៅពេលឈរ។

មានវិធីជាច្រើន ដែលកុមារអាចអនុវត្តការឈរដោយប្រើជង្គង់ និងផ្លាស់ប្តូរទំងន់ ដូចជាវិធីដែលអស់សំណើច និងរួមមានទាំងសកម្មភាពគ្រួសារ។



## ៦. សកម្មភាពសំរាប់ឈរ ដើរ និងលំនឹង

តាមធម្មតាកុមារលូតលាស់តាមរយៈដំណាក់កាលទាំងនេះ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទប់ផ្នែកនៃទំងន់ជាស្វ័យ-ប្រវត្តិនៅពេលកាន់ដូចនេះ | "ការបោះជំហ៊ានដោយស្វ័យប្រវត្តិប្រសិនបើផ្អៀងទៅមុខ | ដាំដូងចុះពេលក្រោកឡើង | ឈរដោយកាន់ទប់ | ទាញឡើងដើម្បីឈរ | បោះជំហ៊ានចំហៀងខ្លួនដោយកាន់ទប់ | បោះជំហ៊ាននៅចន្លោះវត្ថុ | ដើរដោយកាន់ដៃពីរកាន់ដៃមួយ និងចុងក្រោយដើរដោយពុំបាច់កាន់ទប់ |




អ្នករៀបចំកុមារឱ្យដើរ ដោយលើកទឹកចិត្តតាមដំណាក់កាលនីមួយៗដូចខាងលើ នៅពេលដែលកុមារវិវត្ត។

> ***ប្រយ័ត្ន :*** ប្រសិនបើកុមារមិនអាចទប់លំនឹងនៅពេលអង្គុយ ចូរកុំបន្តការដើរ។ ចូរជួយកុមារឱ្យវិវឌ្ឍលំនឹងអង្គុយជាមុន។

ចូរកាន់ទប់ទារក ដើម្បីឱ្យគេប្រើ **ការបោះជំហ៊ានរ៉េផ្លិចដំបូង** ដើម្បីពង្រឹងជើងរបស់គេ។ អ្នកអាចធ្វើឱ្យកុមារលោតដោយថ្នមៗ។



> ***ប្រយ័ត្ន :*** ចំពោះកុមារដែលពិបាក សកម្មភាពនេះអាចកើនការរឹងសាច់ដុំ។ **ចូរកុំធ្វើវា**។ (ចូរមើលទំព័រ ២៥ និង ១១១)

នៅពេលដែលកុមារចាប់ផ្តើមឈរ ចូរទប់ទ្រត្រគាករបស់គេដោយដៃរបស់អ្នក។ ចូរលាតជើងរបស់គេទៅម្ខាងៗដើម្បីអោយទូលាយ។ ដំបូងធ្វើរបៀបនេះពីខាងមុខរួចពីខាងក្រោយ។

ចូរធ្វើចលនាដោយតិចៗពីម្ខាងទៅម្ខាង ដើម្បីឱ្យនាងរៀនប្តូរទំងន់ពីជើងម្ខាងទៅជើងម្ខាង។



នៅពេលដែលគេមានលំនឹងប្រសើរ អ្នកអាចផ្តល់ការទប់ទ្រតិចៗនៅពីលើស្មា។



ឬឱ្យកុមារកាន់តោងទុយោ ឬខ្សែ។ ព្រោះវាមានលក្ខណៈបត់បែនកុមារត្រូវការធ្វើឱ្យមានលំនឹងច្រើន។



ក្រោយមកកុមារអាចតោងខ្សែ ដោយប្រើតែដៃម្ខាង។

ដើម្បីលើកទឹកចិត្តកុមារឱ្យទាញក្រោក ចូរដាក់ប្រដាប់លេងដែលគេចូលចិត្តនៅលើតែមតុ។



ដើម្បីលើកទឹកចិត្តកុមារឱ្យបោះជំហ៊ាន ចូរដាក់ប្រដាប់លេងដែលគេចូលចិត្តនៅលើចុងតុម្ខាងទៀត

នៅពេលដែលកុមារជិតតែចេះដើរដោយឯកឯង ប៉ុន្តែខ្លាចដួល ចូរចងក្រណាត់ជុំវិញទ្រូងរបស់គេ។

ចូរកាន់ខ្សែក្រណាត់នោះ ប៉ុន្តែអោយវា **មានលក្ខណៈធូរខ្លាំង** ចូរប្រុងប្រៀបចាប់គេប្រសិនបើគេដួល។



> ***ប្រយ័ត្ន :*** ចូរកុំឱ្យកុមារទាញទប់ដោយខ្សែក្រណាត់នោះ។ ចូរឱ្យគេទប់ទំងន់ដោយខ្លួនឯង។ ខ្សែក្រណាត់ គ្រាន់តែសំរាប់ចាប់នៅពេលដែលគេដួល។

សកម្មភាពផ្សេងទៀតសំរាប់**កែលំអលំនឹង** :
ចូរកាន់ទប់កុមារ**ដោយរលង់**ពីក្រោមដៃ និង ផ្អៀងគេពីម្ខាងទៅម្ខាង និងពីមុខទៅក្រោយ ។ ចូរអនុញ្ញាតឱ្យគេបែរកទីតាំងត្រង់ ។ ចូរប្រែក្លាយឱ្យទៅជាល្បែងកំសាន្ត ។



ដំបូងចូរទប់កុមារ នៅពេលអ្នកធ្វើដូចនេះ លំនឹងរបស់គេត្រូវបានកែលំអ ចូរធ្វើវាដោយពុំបាច់ទប់ ប៉ុន្តែ ចូរប្រុងប្រៀបចាប់ក្រែងគេដួល ។

ចូរហាត់ដើរចំហៀងខ្លួន និងត្រឡប់ក្រោយ



*ចំណាំ :*
ការដើរត្រឡប់ក្រោយជួយឱ្យកុមារដែលចង់ដើរដោយចុងជើងទំលាក់កែងជើងចុះវិញ ។

ជាការប្រសើរដែលកាន់ទប់កុមារ :



ត្រូវធ្វើដូចនេះ ←

លំនឹងរបស់គេនៅចំ-កណ្តាលកាយរបស់គេ ។

មិនត្រូវធ្វើដូចនេះទេ →

លំនឹងរបស់គេមិននៅចំកណ្តាល ។



**ចូរទប់ទ្រកូនរបស់អ្នក តាមតែគេត្រូវការ** រហូតដល់គេអាចដើរដោយខ្លួនឯងបាន




សំរាប់កុមារ**វ័យច្រើន**ដែលខ្សោយលំនឹង **ក្តារលំនឹង**ដែលធ្វើនៅផ្ទះនឹងប្រែក្លាយការវិវត្តន៍ឱ្យទៅជាល្បែងកំសាន្តប្រសើរឡើង ។ ធ្វើចលនាយឺតៗនៅពេលដំបូង ជាពិសេសចំពោះកុមារដែលខូចខួរក្បាល ។



ចូរដាក់គន្លឹះដើម្បីការពារការរមៀលទៅចំហៀង

ក្តារលំនឹងដែលមានប្រដាប់យោលធំគឺប្រសើរ ព្រោះវាយោលបានរលូនជាង ។

កុមារខ្លះនឹងត្រូវការបង្គោលដើម្បីកាន់នៅលើ



របារស្របគ្នាដែលធ្វើនៅផ្ទះជាសាមញ្ញអាចជួយកុមារដែលខ្សោយជើង ឬមានបញ្ហាលំនឹងអាចចាប់ផ្តើមដើរបាន ។



រទេះរុញ ឬរទេះសំរាប់តោងដើរអាចផ្តល់ការទ្រនិងភាពឯករាជសំរាប់កុមារដែលរៀនដើរ ឬអ្នកដែលមានបញ្ហាលំនឹង ។





ឧបករណ៍សំរាប់តោងដើរធ្វើពីឈើសមញ្ញដែលមានកង់ក្តារបន្ទះជួយកុមារដែលយឺតខាងប្រាជ្ញនេះឱ្យចាប់ផ្តើមដើរ ។ (សំរាប់ការរៀបចំឧបករណ៍សំរាប់តោងដើរ) ។

## ៧. សកម្មភាពសំរាប់ទំនាក់ទំនង និងការនិយាយ

សមត្ថភាពកុមារធម្មតាសំរាប់ធ្វើទំនាក់ទំនងវិវត្តតាមរយៈដំណាក់កាលទាំងនេះ :

| | | | | |
|---|---|---|---|---|
| បង្ហាញតំរូវការតាមរយៈចលនារបស់ទារក ការមើលមុខនិងការស្រែកយំ | ធ្វើឱ្យមាន "សំលេងរីករាយ" ដូចជា គឺៗឬខឹកៗ | និយាយកែករ ដូចជា ស្តាប់សំលេងនិងត្រាប់តាម | និយាយពាក្យពីរ បីមាត់ | ចាប់ផ្តើមបញ្ចូលពាក្យ (និងគំនិត) រួមគ្នា |



| | | | | |
|---|---|---|---|---|
| អាយុ ពី ០-១ ខែ | អាយុ ពី ១-២ ខែ | អាយុ ពី ៤-៨ ខែ | អាយុ ពី ៨-១២ ខែ | អាយុពី ១២ខែ-៣ឆ្នាំ |

ការសិក្សាដែលរៀបចំឱ្យកុមារនិយាយចាប់ផ្តើមដំបូង គឺយូរមុនពេលគេនិយាយពាក្យទីមួយ ។ ការនិយាយវិវត្តក្រៅពីចលនាខ្លួន ចូរប្រើមាត់ និងអណ្តាតក្នុងការញុាំ និងប្រើវិញ្ញាណ ដូចជាតាមរយៈប្រតិកម្មជាមួយមនុស្ស និងវត្ថុ ។

ដំណាក់កាលមួយនៃដំណាក់កាលដំបូងទាំងអស់ នៅក្នុងការវិវត្តន៍នៃការនិយាយរបស់កុមារ គឺការកត់សំគាល់ និងការឆ្លើយតបចំពោះសំលេងផ្សេងគ្នា ។ កុមារយឺតអាចត្រូវការជំនួយ និងការជំរុញបន្ថែម :

ចូរធ្វើសំលេងដោយប្រើកន្តឹង ឬស្គរ ដំបូងធ្វើដោយផ្ទាល់ពីមុខកុមារ បន្ទាប់មកទៅម្ខាងទៀត ដើម្បីឱ្យកុមារងាកក្បាលរបស់គេ ។




ប្រសិនបើកុមារមិនងាកក្បាល ចូរយកប្រដាប់លេងមកវិញដើម្បីឱ្យគេបានឃើញវត្ថុនោះរួចយកវាចេញវិញ ។

ឬត្រឡប់ក្បាលរបស់គេថ្នមៗដើម្បីឱ្យគេឃើញអ្វីដែលបង្កើតសំលេងនោះ ។ ចូរជួយគេតិចទៅៗរហូតដល់គេងាកក្បាលដោយឯកឯង ។

**ចូរថាពាក្យកែកររបស់កុមារ** : ធ្វើការសន្ទនាជាមួយកុមារជាភាសារបស់គេ ។ ប៉ុន្តែនៅពេលគេចាប់ផ្តើមនិយាយពាក្យ ចូរនិយាយតាម និងបញ្ចេញឱ្យបានច្បាស់ និងឱ្យបានត្រឹមត្រូវ **ចូរកុំប្រើ "ភាសាទារក"**



ដើម្បីឱ្យកុមារស៊ាំនឹងភាសា **ចូរពន្យល់អ្វីៗដែលអ្នកធ្វើជាមួយគេ** ។ ចូរប្រើពាក្យឱ្យច្បាស់ និងសាមញ្ញ ជាពាក្យដូចគ្នាក្នុងពេលនីមួយៗ ចូរដាក់ឈ្មោះប្រដាប់លេង វត្ថុផ្នែកនៃសរីរាង្គកាយ ។ ចូរនិយាយច្រំដែលឱ្យបានញឹកញាប់ ។



ដើម្បីយល់ភាសា មិនអាស្រ័យត្រឹមតែការស្តាប់ឮទេ តែក៏អាស្រ័យលើការមើលបបូរមាត់ និងរូបរាង ។ ដូចច្នេះ **ចូរនិយាយទៅកាន់កុមារតាមកំរិតរបស់គេ**



ចូរធ្វើដូចនេះ



ចូរកុំធ្វើដូចនេះ

កុមារយល់ពាក្យមុនពេលគេអាចនិយាយពាក្យទាំងនោះ ។ **ចូរលេងល្បែងសំនួរ** ដើម្បីជួយគេឱ្យស្តាប់និងរៀន ។ គេអាចឆ្លើយសំនួររបស់អ្នកដោយចង្អុល ងក់ក្បាល និងការចាប់ដៃរបស់គេ ។
ចូរនិយាយពាក្យច្រំដែល ។
ចូរបង្កើតសំណើរតូចមួយ ។
ចូរផ្តល់រង្វាន់ដល់ការជ័យជំនះ ។



ចង្វាក់មានសារៈសំខាន់ចំពោះការវិវត្តន៍ភាសា។ **ច្រៀងចំរៀង លេងភ្លេង និងឱ្យកុមារធ្វើត្រាប់ចលនាទារកៈ** ទះដៃ ស្ទាបម្រាមជើង ឬវាយស្គរ



ធ្វើត្រាប់តាមសំលេងទារក និងឱ្យគេចំលងសូរសំលេងឱ្យដូចនៅពេលដែលអ្នកធ្វើវា។ បន្ទាប់មកចូរនិយាយពាក្យដែលស្រដៀងនិងសំលេងទាំងនោះ។

ចូរត្រាប់ការប្រើមាត់ដែរដូចជា ហាមាត់ឱ្យធំ បិទឱ្យជិត លានអណ្តាតចេញ ផ្លុំខ្យល់ រុញបបូរមាត់ចូលក្នុង និងចេញក្រៅ។

*ប្រយ័ត្ន :* ចូរលើកទឹកចិត្តក្នុងការប្រើកាយវិការប៉ុន្តែកុំច្រើនពេកដែលធ្វើឱ្យកុមារមិនមានអារម្មណ៍ត្រូវការព្យាយាមប្រើពាក្យ។



## បញ្ហាពិសេសក្នុងការវិវត្តន៍នៃការនិយាយ

មាត់ដែលចំហរ ឬហៀរទឹកមាត់ គឺជាមាត់អកម្ម (Inactive)។ វាបង្កើតការលំបាកជាច្រើនក្នុងការវិវត្តន៍ភាសា។ កុមារដែលមានសហានិមិត្តហេតុចុះ ឬប្រភេទបបូរធ្លាក់នៃជំងឺខួចខួរក្បាល ជារឿយៗមានបញ្ហានេះ។

នេះជាការស្នើសុំខ្លះៗដើម្បីជួយកែសំរួលបញ្ហានៃការហៀរទឹកមាត់ និងជួយពង្រឹងបបូរមាត់ និងអណ្តាតសំរាប់សមត្ថភាពញ៉ាំ និងនិយាយ។

*ចំណាំ :* មាត់របស់កុមារចំហរនិងកុមារហៀរទឹកមាត់ ចូរកុំប្រាប់ឱ្យគេបិទមាត់! វិធីនេះ នឹងមិនជួយ ហើយគ្រាន់តែធ្វើឱ្យកុមារខកចិត្ត។



អង្អែល ឬវាយផ្ទៃកខាងលើបបូរបន្ថែ្វបួសង្កត់ផ្ទៃក ខាងក្រោមបន្តិចថ្នមៗបីឬបួនដង។



ឬ ទាញពន្លាសាច់ជុំបបូរថ្នមៗ។ វិធីនេះអាចជួយកុមារឱ្យបិទមាត់របស់គេបាន។



ដើម្បីពង្រឹងអណ្តាត និងបបូរមាត់ ចូរដាក់ទឹកឃ្មុំ ឬស្ករ អាហារ ស្អិតពីលើ ឬក្រោម បបូរមាត់។ ចូរឱ្យកុមារលិទ្ធវាឱ្យអស់។







អ្នកអាចដាក់អាហារស្អិតនៅលើខាងក្នុងធ្មេញមុខ ឬប្រអប់មាត់ខាងលើ។ ការលិតអាហារនេះជួយឱ្យរៀបចំអណ្តាតសំរាប់និយាយអក្សរ **T D N G H J** និង **L**

ចូរឱ្យកុមារលិទ្ធអាហារស្អិតពីស្លាបព្រា និងលិត ឬជញ្ជក់ "ស្ករគ្រាប់" និងអាហារផ្សេងទៀត ឬស្ករគ្រប់។



ចូរដាក់អាហារចូលក្នុងផ្នែកនៃមាត់ និងពីក្រោយធ្មេញ ដើម្បី ឱ្យកុមារលំហាត់អណ្តាត។

ចូរឱ្យកុមារព្យាយាមផងដែរញ៉ាំអាហារ ដោយប្រើមាត់។

ចាប់ផ្តើមផ្តល់ឱ្យកុមារនូវអាហាររឹង និងអាហារដែលត្រូវ ការទំពារ តាមតែគេអាចញ៉ាំពីព្រលឹម (បន្ទាប់ពីអាយុ ៤ ខែ)។ វិធីនេះអាចជួយវិវឌ្ឍថ្គាម និងមាត់។

*ប្រយ័ត្ន:* ១. ចូរកុំលំហាត់លិទ្ធជាមួយកុមារដែលមានជំងឺខួចខួរក្បាល ដែលអណ្តាតរបស់គេរុញមកមុខពុំមានការគ្រប់គ្រង។ វិធីនេះអាចធ្វើឱ្យលយចេញអាក្រក់បំផុត។

២. បន្ទាប់ពីឱ្យស្ករ ឬអាហារស្អិតដល់កុមារ ចូរថែរក្សាសំអាតធ្មេញឱ្យបានល្អបន្ថែមទៀត។

ចូរលេងល្បែងដែលអ្នកមានៈ

បឺតនិងផ្លុំពពុះតាមបំពង់បឺត



ចូរផ្លុំពពុះសាប៊ូ



ចូរផ្លុំខ្យល់



ចូរផ្លុំកញ្ចែរ



*ប្រយ័ត្ន :* សំរាប់កុមារដែលមានជំងឺខូចខួក្បាល លំហាត់ផ្លុំទាំងនេះអាចកើនឡើងការបន្តឹងសាច់ដុំ ឬវាំចមាត់ ដែលគេពុំអាចគ្រប់គ្រងបាន ។ ប្រសិនបើដូចនេះ ចូរកុំប្រើវិធីទាំងនេះ ។

ចូរលើកទឹកចិត្តដល់ការធ្វើមាត់ដូចនិយាយ និងទំពាប្រដាប់លេងដែលស្អាត ( ប៉ុន្តែកុំជញ្ជក់មេដៃ)

ចូរជួយកុមាររកវិធីធ្វើសូរសំលេងផ្សេងគ្នាដោយបិទបបូរឡើង និងចុះ ដោយម្រាមដៃរបស់អ្នក



ឬដោយច្របាច់បបូរមាត់ចូលគ្នានៅពេលដែលគេធ្វើសំលេង



ចំពោះកុមារខូចខួរក្បាល អ្នកអាចជួយគេឱ្យគ្រប់គ្រងមាត់សំរាប់ញាំ ឬនិយាយដោយធ្វើឱ្យមានស្ថេរភាពកាយរបស់គេនៅក្នុងទីតាំងរឹងមាំ ។ ចូរជ្រើសរើសទីតាំងដែលឱ្យគេសំរាកបានច្រើន ( លំបាកតិចបំផុត) ។ វិធីនេះជាធម្មតាមានន័យថា ពត់ក្បាល ស្មា និងត្រគាកទៅមុខ ។ ចំពោះហេតុផលនេះជួនកាលវាត្រូវបាននិយាយថា :

**"យើងអាចគ្រប់គ្រងបបូរមាត់តាមរយៈត្រគាក "**។



អ្នកអាចជួយកុមារធ្វើសំលេងផ្សេងៗដោយរុញ ឬធ្វើឱ្យញ័រទ្រូង

ចូរគ្រាប់សំលេងដែលកុមារធ្វើ និងលើកទឹកចិត្តគេឱ្យធ្វើដោយខ្លួនឯង ។

ប្រសិនបើកុមារមានបញ្ហាជាមួយការគ្រប់គ្រងថ្គាមនៅពេលដែលគេព្យាយាមនិយាយ ចូរព្យាយាមប្រើ "**ការគ្រប់គ្រងថ្គាម**" ដោយប្រើម្រាមដៃរបស់អ្នក ។

ឱ្យគេធ្វើសំលេងដដែលៗដែលតំរូវឱ្យមានចលនាថ្គាម ។



នៅពេលដែលកុមារមានការលំបាកបញ្ចេញសូរសំលេង **ចូរកុំកែតំរូវគេ** ។ ជាជំនួស ចូរនិយាយពាក្យច្រំដែលៗត្រឹមត្រូវ និងច្បាស់លាស់ដោយបង្ហាញថាអ្នកយល់ ។



*ចូរចងចាំ :* កុមារត្រូវការការជំរុញនៃវិញ្ញាណទាំងអស់ដើម្បីវិវត្តភាសា ។ ចូរលេងជាមួយគេ និយាយទៅកាន់គេ និងច្រៀងទៅកាន់គេឱ្យបានញឹកញាប់ ។ ចូរសួរសំនួរនិងផ្តល់ពេលដល់គេសំរាប់ឆ្លើយ ។ **ចូរកុំព្យាយាម "ធ្វើឱ្យគេរៀន" ប៉ុន្តែផ្តល់ឱកាសសិក្សាជាច្រើន** ។ ចូរសួរសំនួរដែលត្រូវការពាក្យសំរាប់ឆ្លើយមិនមែនគ្រាន់តែពាក្យ "បាទ/ចាស៎" និង "ទេ" ឡើយ ។

**តើកូនរបស់អ្នកថ្លង់ឬ?** ប្រសិនបើកូនរបស់អ្នកយឺតក្នុងការនិយាយ ចូរពិនិត្យការឮរបស់គេ ។ បើទោះជាគេឮសំលេងខ្លះក៏ដោយ គេអាចពុំឮបានល្អគ្រប់គ្រាន់ដើម្បីយល់ពីការនិយាយ ។

កុមារមួយចំនួនដែលឮបានល្អអាចមិនដែលមានសមត្ថភាពនិយាយ ។ ឧទាហរណ៍ កុមារខ្លះដែលមានជំងឺខូចខួរក្បាលមិនអាចគ្រប់គ្រងមាត់ អណ្តាត ឬសាច់ដុំសំលេងរបស់គេបាន ។ ចំពោះកុមារដែលថ្លង់ពីក្មេង យើងត្រូវតែស្វែងរកវិធីផ្សេងៗដើម្បីធ្វើទំនាក់ទំនង ។

## ៨. សកម្មភាពលេង និងប្រដាប់លេងដំបូង

លេងជាវិធីដែលកុមាររៀនបានល្អបំផុត ។ **ដូចនេះ ចូរព្យាយាមប្រែក្លាយរាល់សកម្មភាពដែលអ្នកធ្វើជាមួយកុមារ ឱ្យទៅជាប្រភេទនៃការលេង ឬប្រភេទនៃល្បែង** ។

វាមិនមែនជាអ្វីដែលអ្នកធ្វើទេ ប៉ុន្តែ**ជាវិធីដែលអ្នកធ្វើ** ដែលបង្កើតឱ្យអ្វីមួយលេង ។ ដរាបណាវាជារឿងអស់សំណើច ហើយកុមារចង់ធ្វើវានោះវាជាល្បែងហើយ ។ ប៉ុន្តែបើវាជារឿងមិនអស់សំណើច ឬក៏កុមាធ្វើវាដោយសារតែ "គេត្រូវតែធ្វើ" នោះវាមិនមែនជាល្បែងទេ ។ កុមារតូចៗ (និងកុមារធំៗដែលរៀនយ៉ាងយឺត) គ្រាន់តែចូលចិត្តចំពោះរឿងដូចគ្នាតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ កុមារនឹងមានការធុនទ្រាន់ភ្លាមៗ រួចឈប់រៀន ។ អាស្រ័យហេតុនេះ ចំពោះសកម្មភាពលេងកំសាន្ត និង និងនៅតែលេង :

១. ចូរបន្តជាមួយសកម្មភាពដដែលតែក្នុងរយៈដ៏ខ្លី

២. ចូរស្វែងរកវិធីដើម្បីបន្តការផ្លាស់ប្តូរសកម្មភាពបន្តិចបន្តួច ដើម្បីឱ្យវាថ្មីជានិច្ច និងគួរឱ្យចាប់អារម្មណ៍ ។




កុមារាទាំងពីរនៅក្នុងរូបភាពនេះកំពុងធ្វើសកម្មភាពរៀនដូចគ្នា ។ ឯម្នាក់កំពុងលេង និងម្នាក់ទៀតមិនលេងទេ ។ តើអ្នកអាចនិយាយថាដោយសារតែហេតុអ្វីទេ?



មិនមែនគ្រប់ការលេងកំសាន្តទាំងអស់ត្រូវតែគេរៀបចំ ឬធ្វើផែនការទេ ជារឿយៗកុមាររៀនភាគច្រើន នៅពេលដែលវាមិនមែនជាការលេង ។ ការលេងកំសាន្តត្រូវការទិដ្ឋ**ភាពផ្សងព្រេង ភាពភ្ញាក់ផ្អើល** និង**សេរីភាព**មួយចំនួន ។ ជាការសំខាន់ដែលកុមាររៀន**លេងជាមួយកុមារដទៃ** ។ ប៉ុន្តែសំខាន់ផងដែរ ដែលគេត្រូវបានផ្តល់ឱកាស និងលើកទឹកចិត្ត**លេងកំសាន្តតែម្នាក់ឯង** ។ កុមារត្រូវការលេងដើម្បីគាប់ចិត្តរីករាយ និងរស់នៅជាមួយមនុស្សដទៃ ក៏ដូចជាមួយខ្លួនរបស់គេផ្ទាល់ ។

យើងមិនត្រូវនិយាយច្រើនពីការលេងដោយឡែកៗ ពីព្រោះភាគច្រើនវាមិនមែនជាសកម្មភាពដោយឡែកឡើយ ។ ជាវិធីដ៏ល្អបំផុតដែលធ្វើស្ទើរតែរាល់សកម្មភាព ។ ចំពោះហេតុផលនេះ មាននៅក្នុងជំពូកទាំងមូល និងក្នុងសៀវភៅ ជាញឹកញាប់យើងផ្តល់គំនិតសំរាប់ប្រែក្លាយលំហាត់ប្រាណ វិធីព្យាបាល និងការសិក្សាឱ្យទៅជាការលេងកំសាន្ត ។

**ចូរលេងសកម្មភាពផ្សេងៗដូចសកម្មភាពដទៃទៀត គួរត្រូវបានជ្រើសឡើងដើម្បីឱ្យសាកសមនិងកំរិតនៃការវិវត្តន៍របស់កុមារ និងជួយគេឱ្យធ្វើចលនាមួយជំហ៊ានម្តងៗជាបន្ថែម ។ សកម្មភាពទាំងនោះគួរតែលំបាកល្មមក្នុងការចាប់អារម្មណ៍ ប៉ុន្តែងាយល្មមក្នុងការធ្វើឱ្យបានល្អ** ។

ប្រសិនបើកុមារនៅកំរិតជាទារកតូច ចូរលេងល្បែងដែលជួយគេឱ្យប្រើភ្នែករបស់គេ និងទប់ក្បាលរបស់គេឡើង ។



ប្រសិនបើកុមារនៅកំរិតដែលគេអង្គុយប៉ុន្តែយល់ថាពិបាកទប់លំនឹង ឬលាជង្គង់របស់ខ្លួនចូរស្វែងរកល្បែងដែលជួយគេដោយវិធីទាំងនេះ




ប្រសិននៅក្នុងការរៀបចំឱ្យអង្គុយ ឬដើរ កុមារត្រូវការហ្វឹកហាត់ការផ្លាស់ប្តូរទំងន់ពីជង្គង់ម្ខាងទៅម្ខាងទៀត ។ អ្នកអាចព្យាយាមត្រាប់ល្បែង ។ នេះជាគំនិតពីរ :





## តុក្កតា និងវត្ថុលេងជំរុញវិញ្ញាណកុមារ

ល្បែងមានសារៈសំខាន់ជាងតុក្កតា។ ស្ទើរតែអ្វីៗទាំងអស់ដូចជា ចូផ្កា ស្បែកជើង ផ្លែឈើ កូនសោ ដែកក្រចកជើងសេះ អាចត្រូវបានប្រើជាតុក្កតា ប្រសិនបើវាត្រូវបានប្រើជាវត្ថុលេង។

តុក្កតាឬវត្ថុលេងផ្សេងៗ ផ្ដល់ការជំរុញសំរាប់កុមារទាំងនៅពេលគេលេងដោយខ្លួនឯង និងទាំងនៅពេលគេលេងជាមួយអ្នកដទៃ។ វត្ថុធម្មតាជាច្រើននៅក្នុងផ្ទះអាចត្រូវបានប្រើជាតុក្កតា ឬអាចត្រូវគេប្រែក្លាយជាតុក្កតាបាន។

ចូរព្យួរប្រដាប់លេងសំរាប់ទារកដើម្បីសរសើរប៉ះ និងកាន់ ដែលអាចត្រូវបានធ្វើឡើងពីវត្ថុជាច្រើន




ខ្នារអំបោះ ចំណិតដបជ័រ គម្របដបដែលធ្វើពីដែក




ការថែរក្សាទារក ផ្ដល់នូវបទពិសោធ-ន៍ សិក្សាដែល គួបពាក្យ និងការ លេងសំរាប់កុមារ ដែលសុភាព



*ប្រយ័ត្ន :* ចូរថែរក្សាប្រដាប់លេងនោះឱ្យស្អាត និងសុវត្ថិភាពសំរាប់កុមារ

នេះជាឧទាហរណ៍មួយចំនួននៃប្រដាប់លេងដែលគួឱ្យចាប់អារម្មណ៍។ ចូរប្រើការស្រមៃរបស់អ្នកនិងធនធានរបស់គ្រួសារ ដើម្បីបង្កើតប្រដាប់លេងៈ

**ប្រដាប់លេងសំរាប់ប៉ះ**

សំលៀកបំពាក់ទុនៗ ឬក្រួយ
កូនសត្វ
ពោតទាំងស្នូល
ថ្នាំក្រចក
បំពង់សំរាប់ហែល
និងងូតទឹក
គ្រប់ និងក្បាលខ្មៅ
ស្រោមជើង និងស្រោមដៃ
សំបកគ្រប់
អាហារគ្រើមៗ
កូនក្រមុំ
ត្រសក់
ដីខ្សាច់

ដីស
ខ្សែ-
ច្រវ៉ាក់
រ៉ែត
ស្ពឹចត្រូ
ថ្ម
អង្កាំ
ផ្លែឈើ
ភក់

ផ្កា
ម្សៅលាយទឹក







ចំពោះកុមារដែលមានបញ្ហាក្នុងការគ្រប់គ្រងចលនារបស់ខ្លួន និងបោះ-បង់ ឬបាត់ប្រដាប់លេងរបស់ខ្លួន វាអាចជួយចងប្រដាប់លេងនិងខ្សែ ដូចបានបង្ហាញនៅទីនេះ។

**ប្រដាប់លេងភ្លក់រសជាតិ និងក្លិន**

អាហារ
ផ្កា
ផ្លែឈើ
សត្វ
គ្រឿងទេស
ទឹកអប់



**ឧបករណ៍លេងសំរាប់មើល**

កញ្ចក់
ពណ៌
ក្រដាស ឬស័ង្កសីបត់ពណ៌
សកម្មភាពគ្រួសារប្រចាំថ្ងៃ
អាយ៉ង
ទស្សនាវដ្ដីចាស់ដែលមានរូបភាព
ដុំកញ្ចក់ត្រីស្ដាល់ (អ្នកបង្កើតពណ៌ឥន្ទ្រ)
ភ្លើងភ្លឺបភ្លែត (ស្ថាប)



ស្រោមអាយ៉ង

**ឧបករណ៍សំរាប់លំនឹង**

ទោង
អង្រឹង
ក្តារជិះបះចុះឡើង
សេះឈើ



**ឧបករណ៍សំរាប់ឮ**

ប្រដាប់អង្រួនលេង
ហ្គីតា
ក្លុយ
ស្គរ
កន្ទឹង
ខ្សែកពាក់
 លើដៃទារក
 និងកជើង
 ដែលឮក្រឹងៗ
 នៅពេលកុមារ
 ធ្វើចលនា

ម៉ារីមបា ឬ
ហ្សីឡូហ្វូន
កន្ទឹងខ្យល់
កញ្ចែ
សត្វចិញ្ចឹម
សំលេងសត្វ
ខ្យងសមុទ្ទ ឬ
 សំលេងខ្ទរផ្សេង
ការជជែក
សើច
ច្រៀង

យកឆ្នាំង
ធ្វើជាស្គរ







កំប៉ុងអាចទូរស័ព្ទបាន
ខ្សែ ឬខ្សែភ្លើង លាអោយតឹង

## ប្រដាប់លេងសំរាប់វិចក្ខុសតិ និងសហការដៃ-ភ្នែករបស់កុមារ

## រៀនធ្វើវត្ថុឱ្យសមល្មមដាក់ចូលក្នុងវត្ថុផ្សេងទៀត

ចាប់ផ្តើមសាមញ្ញដោយទំលាក់វត្ថុទៅក្នុងក្រឡក្រោយមកយកវាចេញវិញ



នៅពេលដែលកុមារវិវ ចូរបង្កើតឱ្យមានវត្ថុស្មុគស្មាញច្រើន




*ចំណាំ :* ជញ្ជៀនអាច មានទំហំ ពណ៌ ទ្រង់ទ្រាយ ផ្សេងគ្នា ដើម្បីឱ្យកុមារអាចរៀនផ្គូផ្គងដែរ ។

ដើម្បីជួយវិវត្តចលនាគ្រប់គ្រងដៃកុមារអាចបង្វិលអង្កាំ ឬប្លុកតាមបណ្តោយដែកវែងឬខ្សែ



ការប្រើសត្វ ឬរូបកំប្លែងធ្វើឱ្យលំហាត់មានការរីករាយ ។ កុមារផ្សេងនឹងទំនងជាចូលរួមក្នុងល្បែងនេះ



## វិធីផ្គុំល្បែង

កុមារអាចផ្គុំវត្ថុដែលមានទ្រង់ទ្រាយ ទំហំ និងពណ៌ប្រហាក់ប្រហែលគ្នា



រូបសត្វជ្រូកតូចដែលបិទការនៅលើផ្ទៃកដែលកាត់ចេញជួយវិវត្តការគ្រប់គ្រងដៃបានល្អ



ចាប់ផ្តើមជាមួយល្បែងសាមញ្ញ ដោយមានប្រអប់បួនជ្រុង ឬរូបជុំវិញ




ការរីកលូតលាស់ចំពោះល្បែងស៊ាំញ៉ាំ ដែលមានរូបទ្រង់ទ្រាយផ្សេងៗ










## ប្រស្នា

ល្បែងផ្គុំរូប និងល្បែងប្លុក និងល្បែងស្ថាបនាប្លុកជួយកុមារឱ្យរៀនផងដែរ ពីទ្រង់ទ្រាយ និងពណ៌សមគ្នាយ៉ាងណា ។ ការស្នើសុំសំរាប់ការបង្កើតប្រស្នាផ្សេងៗ ។



គំនិតជាច្រើនសំរាប់ប្រដាប់លេងសាមញ្ញដែលរួមមានស្តីពីរោងជាងរបស់កុមារសំរាប់បង្កើតប្រដាប់លេង ។